ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០២២/២១ - ញូហ្វីម៉ា២ ខសធ្យូម

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ញូហ្វីម៉ា២ ខសធ្យូម(ខេមបូឌា)(ញូហ្វីម៉ា ខសធ្យូម(ខេមបូឌា))**

អាសយដ្ឋាន ៖ ភូមិកាកាប សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖០៧៧ ៧២៥ ១៣០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោកស្រី ហ៊ែល ផល្លា ប្រធានរដ្ឋបាល

២- លោកស្រី អ៊ុក សោភ័ន្ត រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃ ក្រុមហ៊ុន ញូហ្វីម៉ា២ ខសធ្យូម(ខេមបូឌា)(ញូហ្វីម៉ា ខសធ្យូម(ខេមបូឌា))**

អាសយដ្ឋាន ៖ ភូមិកាកាប សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥០០ ២៨២ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖ **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ស្នើសុំឱ្យក្រុមហ៊ុនកុំឱ្យមានការរើសអើងសហជីព និងមិនត្រូវបញ្ឈប់កម្មករ ឬតំណាងសហជីព ដែលខុសច្បាប់ក្រសួងការងារ។

២- ស្នើសុំឱ្យក្រុមហ៊ុនជួយដាក់ពេទ្យនៅក្រុមហ៊ុន។



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៣- ស្នើសុំឱ្យក្រុមហ៊ុនជួយធ្វើប័ណ្ណ ប.ប.ស ឱ្យបងប្អូន កម្មករ-កម្មការិនី ទាំងអស់គ្នា។

៤- ស្នើសុំឱ្យក្រុមហ៊ុនជួយរៀបចំតុបាយ និងកន្លែងហូបបាយ ជូនបងប្អូនកម្មករ-កម្មការិនី ឱ្យបាន សមរម្យ។

៥- ស្នើសុំឱ្យក្រុមហ៊ុនដាក់ទឹកស្អាតសម្រាប់បរិភោគ តាមអាគារនីមួយៗ ដើម្បីឱ្យកម្មករ-កម្មការនី បាន ហូបគ្រប់គ្រាន់។

៦- ស្នើសុំឱ្យក្រុមហ៊ុនបើកលុយជូនកម្មករ-កម្មការិនី ឱ្យបានទៀតទាត់ថ្ងៃទី២៥ និងថ្ងៃទី១០ ដូចដែល បានកំណត់។

៧- ស្នើសុំឱ្យក្រុមហ៊ុនជួយរៀបចំបន្ទប់បំបៅដោះកូនជូនកម្មករ-កម្មការិនី។

៨- ស្នើសុំឱ្យក្រុមហ៊ុនជួយរៀបចំធុងបាសតាមអាគារនីមួយៗជូនបងប្អូន កម្មករ-កម្មការិនី។

៩- ស្នើសុំឱ្យក្រុមហ៊ុនកុំបង្ខិតបង្ខំបងប្អូន កម្មករ-កម្មការិនី ឱ្យធ្វើការបន្ថែមម៉ោង ដោយមិនមានគោល ការណ៍ស្ម័គ្រចិត្ត។

១០- ស្នើសុំឱ្យក្រុមហ៊ុនជួយរៀបចំសៀវភៅការងារជូនបងប្អូន កម្មករ-កម្មការិនី។

១១- ស្នើសុំឱ្យក្រុមហ៊ុនជួយណែនាំផ្នែករដ្ឋបាលខ្មែរ ឱ្យប្រើពាក្យសម្ដីមកលើបងប្អូន កម្មករ-កម្មការិនី ឱ្យបានសមរម្យ និងមានសុជីវធម៌ល្អ។

១២- ស្នើសុំកុំឱ្យក្រុមហ៊ុន នៅពេលដែលកម្មករ-កម្មការិនី ធ្វើការបន្ថែមម៉ោង ៨យប់ សូមទុកពេលឱ្យ បងប្អូន កម្មករ-កម្មការិនី បានសម្រាក ៣០នាទី ដើម្បីហូបបាយ និងមិនកាត់ម៉ោងបន្ថែមរបស់កម្មករឡើយ។

១៣- ស្នើសុំឱ្យក្រុមហ៊ុនជួយណែនាំប្រធានក្រុមខ្មែរ និងប្រធានស៊ុប កុំជេរប្រមាថប្រើពាក្យសម្ដីមិនល្អ ដាក់កម្មករ-កម្មការិនី។

១៤- ស្នើសុំឱ្យក្រុមហ៊ុនជួយរៀបចំកន្លែងដាក់ម៉ូតូជូនកម្មករ-កម្មការិនី ឱ្យបានត្រឹមត្រូវ។

១៥- ស្នើសុំឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ថ្លៃបាយថ្ងៃគ្រង់បន្ថែម១០០០រៀលទៀត លើប្រាក់ដែលមានស្រាប់។

១៦- ស្នើសុំឱ្យក្រុមហ៊ុនផ្ដល់នូវប្រាក់រង្វាន់ និងអត្ថប្រយោជន៍ផ្សេងៗប្រចាំខែរបស់កម្មករ-កម្មការិនី ជា ធម្មតាឡើងវិញ ក្រោយពីបានផ្អាកអស់មួយរយៈពេល។

១៧- ស្នើសុំឱ្យក្រុមហ៊ុនទុកពេលវេលា១០នាទី នៅចុងម៉ោងធ្វើការ ដើម្បីការសម្អាតម៉ាស៊ីន និងកន្លែង ធ្វើការ។

១៨- ស្នើសុំឱ្យក្រុមហ៊ុនបញ្ឈប់ការកាត់លុយចំនួន ៧ថ្ងៃ រាល់កម្មករដែលបានដាក់ច្បាប់លាលែងពី ការងារ និងសុំឱ្យបើកប្រាក់ខែសរុបចុងក្រោយ នៅថ្ងៃនោះតែម្ដង។

១៩- ស្នើសុំឱ្យក្រុមហ៊ុនជួយផ្ដល់ច្បាប់ឈឺដែលមានសំបុត្រពេទ្យបោះត្រា ប.ប.ស ឱ្យច្បាប់សម្រាក មានប្រាក់ឈ្នួលដល់កម្មករ-កម្មការិនីឡើងវិញ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល

លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក)នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ញូហ្វ៊ីម៉ា២ ឧសធ្យូម(ខេមបូឌា) (ញូហ្វ៊ីម៉ា ឧសធ្យូម(ខេមបូឌា)) លេខ ៥៣៣ ក.ប/អក/វក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្ដឹងរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការទាមទាររបស់កម្មករនិយោជិត សុំឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ២០ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សានៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ពីព្រោះភាគីនិយោជកមិនបានចូលរួម។ យោងតាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ញូ ហ្វ៊ីម៉ា២ ឧសធ្យូម ខេមបូឌា (ញូ ហ្វ៊ីម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក) លេខ ៥៣៣ ក.ប/អក/វក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១។ សម្រាប់ចំណុចទាមទារទី១ ដែលភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិត ដែន ស៊ាប ដែលជាប្រធានសហជីពប្រជាធិបតេយ្យសំណាងកម្មករ ឱ្យចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល រហូតដល់ថ្ងៃចូលធ្វើការវិញ គឺភាគីកម្មករនិយោជិតបានស្នើសុំដកការទាមទារនេះ ដើម្បីប្ដឹងដាច់ដោយឡែកទៅអធិការការងារ ផ្អែកតាមមាត្រា ៤៣ នៃច្បាប់ស្ដីពីសហជីព។ ចំណុចមិនសះជា ចំនួន ១៩ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ញូ ហ្វ៊ីម៉ា២ ឧសធ្យូម ខេមបូឌា (ញូ ហ្វ៊ីម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក) លេខ ៥៣៣ ក.ប/អក/វក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាទាំង ១៩ចំណុចនេះ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក តាមរយៈលិខិតអញ្ជើញលេខ ០៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែសីហា

THE ARBITRATION COUNCIL

ឆ្នាំ២០២១ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ០៩៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១២១ ទៅភាគីកម្មករនិយោជិត។

នៅថ្ងៃសវនាការ នៅវេលាម៉ោង ៧ និង ២២ នាទីព្រឹក លោក ឈុន បូរី ជាមន្ត្រីសហព័ន្ធសហជីព ដែលអមតំណាងភាគីកម្មករនិយោជិតក្នុងសំណុំរឿងនេះ បានទំនាក់ទំនងមកមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាលតាមរយៈប្រព័ន្ធតេឡេក្រាម ដើម្បីស្នើសុំពន្យារពេលសវនាការ ដោយមូលហេតុថា តំណាងភាគីកម្មករនិយោជិតទាំងអស់ គឺត្រូវបាននិយោជកបញ្ឈប់ និងកំពុងធ្វើការនៅក្រុមហ៊ុនថ្មី ហើយពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យឈប់សម្រាក ដើម្បីមកចូលរួមសវនាការនេះទេ។ បន្ទាប់មក មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងតាមទូរសព្ទទៅតំណាងភាគីកម្មករនិយោជិត លោកស្រី ដែន ស៊ាប និងលោកស្រី វ៉ែន សុខនីន ហើយគាត់ទាំងពីរនាក់បានបញ្ជាក់ដូចគ្នានឹងអ្វីដែលមន្ត្រីសហព័ន្ធបានប្រាប់មកមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។ នៅថ្ងៃសវនាការ គឺមានវត្តមានរបស់លោកស្រី ហ៊ែល ផ្លា និងលោកស្រី អ៊ុក សោភ័ន្ត ដែលជាអ្នកតំណាងភាគីនិយោជក ប៉ុន្តែពួកគាត់ទាំងពីរបានលើកឡើងថា ពួកគាត់មកចូលរួមសវនាការថ្ងៃនេះ មិនមែនមកតំណាងឱ្យនិយោជកក្នុងសំណុំរឿងនេះទេ គឺពួកគាត់មកនេះ ដើម្បីបញ្ជាក់ចំពោះមុខក្រុមអាជ្ញាកណ្តាលថា ភាគីកម្មករនិយោជិតបានដាក់បណ្តឹងខុសឈ្មោះក្រុមហ៊ុនតែប៉ុណ្ណោះ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃអង្គារ ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់ក្រុមហ៊ុន ញូហ្វ៊ូម៉ា ខសធ្យូម គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោកស្រី ហ៊ែល ផល្លា និងលោកស្រី អ៊ុក សោភ័ន្ត ជាអ្នកតំណាង ដែលមានសិទ្ធិ និងអំណាចពេញលេញ ក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ។

២- លក្ខន្តិកៈក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក បានតំកល់ទុកលេខ ០០០២៧២០ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក បានចុះទិដ្ឋាការលេខ E1IR20210105 អធក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ចេញដោយនាយកដ្ឋានអធិការកិច្ចការងារ។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក លេខ MOC-62406191 ពណ.ចបព ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧។

៥- លិខិតលេខ ០១៨៣ ព.ណ.ចបព ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជម្រាបមក អភិបាលក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក ស្តីពីសុំពង្រីកបន្ថែមអគារផលិតកម្មរោងចក្រកាត់ដេរសម្លៀកបំពាក់ (មុខសញ្ញាដដែល) នៅលើទីតាំងថ្មី។

៦- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក "សាខាទី១" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១។

៧- ប្រកាសបង្កើតសាខារោងចក្រ ញូ ហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក របស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លេខ ១៧២ ឧវបន.កឧ.ប្រក. ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២១។

៨- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងសហគ្រាស ញូ ហ្វ៊ូម៉ា២ ឧសធ្យូម (ខេមបូឌា) ឯ.ក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១។

៩- លិខិតបដិសេធរបស់នាយកក្រុមហ៊ុន ញូ ហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា) ឯ.ក (សាខាទី១) គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសុំបដិសេធមិនចូលរួមដោះស្រាយពាក់ព័ន្ធពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូហ្វ៊ូម៉ា២ ឧសធ្យូម (ខេមបូឌា) (ញូហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា)) លេខ ៥៣៣ ក.ប/អក/វក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ញូហ្វ៊ូម៉ា២ ឧសធ្យូម (ខេមបូឌា)(ញូហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា)) ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ញូហ្វ៊ូម៉ា២ ឧសធ្យូម (ខេមបូឌា)(ញូហ្វ៊ូម៉ា ឧសធ្យូម (ខេមបូឌា)) លេខ ០៣២/២១ កប/អក/វក/កវក២ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៩៦ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៩៧ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីកម្មករនិយោជិតដែលជាដើមបណ្តឹង មិនបានចូលរួមក្នុងនីតិវិធីសវនាការ។

THE ARBITRATION COUNCIL

## ហេតុផលនៃសេចក្តីសម្រេច ÷

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានរបស់ភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

ប្រការ ២១ នៃប្រកាសដដែល ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា លក្ខខណ្ឌបីត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ, លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសគី, លេខ ២៧/០៧-អ៊ឹម និង រ៉េ ៣, លេខ ៩៥/ ០៨-យ៉ុង រ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិលសិន, លេខ ០៩/០៩-នីមបឹស ចិចថាយ៍, លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-ក្លប៍ល អាប៉ារែល, លេខ ១៣០/១៣-យែន ដើរេន អីកែវីល, លេខ ១៦៧/១៣-ឃ្វីនជ៍ មេជើរ អ៊ិនដាសស្ទ្រៀល និងលេខ ២៧០/១៣-៨ ស្តារ ស្តតវែរ)*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

### លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត ដើម្បីឱ្យមកចូលរួមក្នុងសវនាការអាជ្ញាកណ្តាលយ៉ាងត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៥០៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១។ នៅក្នុងលិខិតនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីកាលបរិច្ឆេទនៃសវនាការ គឺនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ដដែល មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា-

កណ្តាលបានទាក់ទងទៅកាន់តំណាងកម្មករនិយោជិតចំនួន ២រូប គឺលោកស្រី ដែន ស៊ាប និងលោក ឈុន បូរី ដើម្បីប្រាប់ពីថ្ងៃសវនាការ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងតាមប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលតម្រូវឱ្យភាគីត្រូវបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលនោះ គឺភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។

ក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនមានវត្តមាននៅក្នុងសវនាការទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារប្រការ ២១ នៃប្រកាសលេខ ០៩៩ លើនេះទេ។ ដូចនេះ លក្ខខណ្ឌទី២ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការទេ ដោយបានបញ្ជាក់តាមទូរសព្ទ និងប្រព័ន្ធតេឡេក្រាម ជាមួយមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលថា តំណាងភាគីកម្មករនិយោជិតទាំងអស់ គឺត្រូវបាននិយោជកបញ្ឈប់ និងកំពុងធ្វើការនៅក្រុមហ៊ុនថ្មី ហើយពួកគាត់មិនត្រូវបានអនុញ្ញាតឱ្យឈប់សម្រាក ដើម្បីមកចូលរួមសវនាការនេះទេ។ បន្ថែមពីនេះ ភាគីកម្មករនិយោជិតមិនបានដាក់លិខិតស្នើសុំមកក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនថ្ងៃសវនាការក្នុងរយៈពេលសមស្របមួយ ដើម្បីស្នើសុំពន្យារពេលសវនាការ ដោយបញ្ជាក់ពីមូលហេតុត្រឹមត្រូវនោះទេ។ ហេតុនេះ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដើមបណ្តឹងមិនមានហេតុផលត្រឹមត្រូវសម្រាប់ការមិនមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ដូច្នេះ លក្ខខណ្ឌទី៣ ត្រូវបានបំពេញ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបី ដែលមានចែងក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ ខាងលើ ត្រូវបានបំពេញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមនីតិវិធីនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ភាគីដើមបណ្តឹង និងភាគីចុងចម្លើយនៃសំណុំរឿងវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល មានកាតព្វកិច្ចបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីបកស្រាយ បង្ហាញ និងផ្តល់អំណះអំណាង សម្រាប់ការទាមទាររបស់ខ្លួន ក៏ដូចជាផ្តល់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗ ដែលពាក់ព័ន្ធនឹងចំណុចវិវាទ សម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងសម្រេចសេចក្តី។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងទាមទាររបស់ខ្លួន។ ចំណែកឯភាគីចុងចម្លើយមានកាតព្វកិច្ចផ្តល់អំណះអំណាង ហេតុផល និងភស្តុតាងដែលពាក់ព័ន្ធនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះបន្ទុករបស់ខ្លួន ពីការទាមទារពីសំណាក់ដើមបណ្តឹង។

ក្នុងសំណុំរឿងនេះ ភាគីដើមបណ្ដឹង និងភាគីចុងចម្លើយមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្ដល់អំណះអំណាង ហេតុផល និងភស្ដុតាង ដើម្បីការពារបណ្ដឹងរបស់ខ្លួនទេ។ លើសពីនេះ ភាគីដើមបណ្ដឹងក៏មិនមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា ភាគីដើមបណ្ដឹងបានបោះបង់ចោលការទាមទាររបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនចាំបាច់បន្តដំណើរការអាជ្ញាកណ្ដាលនោះទេ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា ដើមបណ្ដឹងបានបោះបង់ចោលពាក្យបណ្ដឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាល ដោយចេញជាសេចក្ដីបង្គាប់។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០២២/២១-ញូ ហ្វ៊ូម៉ា២ ខសធ្យូម ខេមបូឌា (ញូ ហ្វ៊ូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក) នេះ។

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០២២/២១-ញូ ហ្វ៊ូម៉ា២ ខសធ្យូម ខេមបូឌា (ញូ ហ្វ៊ូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុំខ សុទ្ធី**

ហត្ថលេខា ៖ -----------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖-----------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **គង់ ឆល្លៈ**

ហត្ថលេខា ៖ -----------------------------

THE ARBITRATION COUNCIL